ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍
និងគ្រឿងញៀន
លេខៈ ០៤៧ កប/គបអគញ

**សូមគោរពជូន**
**ឯកឧត្តមទេសរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**កម្មវត្ថុៈ** របាយការណ៍បូកសរុបលទ្ធផលការងារស្តីពីការបង្ការនិងការប្រយុទ្ធទប់ស្កាត់ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ និងគ្រឿងញៀនប្រចាំនព្វមាស និងទិសដៅអនុវត្តត្រីមាសទី៤ ឆ្នាំ២០១៧។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍សូមជម្រាបជូន **ឯកឧត្តមប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** មេត្តាជ្រាបដូចខាងក្រោមៈ

**ក- លទ្ធផលការងារដែលសម្រេចបាន**

**I-ការប្រជុំ និងការងារផ្សេងៗរបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង**

-កិច្ចប្រជុំប្រចាំត្រីមាសរបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀនក្រោមអធិបតីភាព ឯកឧត្តមវេជ្ជ. **ហ៊ុយ ហានសុខ** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀន សរុបសមាជិកចូលរួម ៣០ នាក់ (ស្រី ១៣នាក់) ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ នៅអគារទីស្តីការក្រសួង។

-កិច្ចប្រជុំចំនួន ៣ លើករៀបចំសេចក្តីព្រាង សេចក្តីណែនាំ ស្តីពីយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១ នៅកម្ពុជា នៅលេខាធិការដ្ឋានអេដស៍ និងគ្រឿងញៀន ទីស្តីការក្រសួង។

-បានបោះពុម្ពសៀវភៅគោលការណ៍ណែនាំប្រកាសលេខ១៩៤ ក.ប/ប្រ.ក ស្តីពីលក្ខខណ្ឌការងារ វិធានអនាម័យ និងសន្តិសុខការងារនៃសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនផ្នែកសេវាកម្សាន្ត ចំនួន៥.០០០ ក្បាល។

-កិច្ចប្រជុំផ្លូងសេចក្តីណែនាំស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នៅតាមសហគ្រាស គ្រឹះស្ថាន ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៧ នៅទីស្តីការក្រសួង។

-កិច្ចប្រជុំគណៈកម្មការសម្របសម្រួលគម្រោងបណ្ណាល័យមណ្ឌលធនធាន ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៧ នៅទីស្តីការក្រសួង ក្រោមកិច្ចសហការជាមួយអង្គការ SIPAR ។

-បានជួបប្រជុំជាមួយក្រុមការងារកសាងកម្រងព័ត៌មានជាតិស្តីពីសារធាតុ អាសបេស្តុសនៃព្រះរាជាណាចក្រកម្ពុជាពីក្រសួងពាក់ព័ន្ធស្តីពីពីសារធាតុអាសបេស្តុសរួមមានក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងរ៉ែ និងថាមពល ក្រសួងកិច្ចការនារី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពីថ្ងៃទី១៤-២០ ខែមីនា ឆ្នាំ២០១៧ នៅទីស្តីការក្រសួង។

-ប្រជុំជាមួយអង្គការ RHAC ស្តីពីការរៀបចំគម្រោងផែនការគ្រួសារ ថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ នៅទីស្តីការក្រសួង។

-ថ្នាក់ដឹកនាំ និងសមាជិករបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងចុះផ្សព្វផ្សាយ និងណែនាំការចុះជំរុញការអនុវត្តប្រកាសលេខ ០៨៦ ក.ក.ប.វ/ប្រ.ក ស្តីពីការបង្កើតគណៈកម្មការអេដស៍នៅតាមសហគ្រាស គ្រឹះស្ថាន ប្រកាសលេខ ១៩៤ ក.ប/ប្រ.ក ស្តីពីលក្ខខណ្ឌការងារ វិធានអនាម័យ និងសន្តិសុខការងារនៃសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនផ្នែកសេវាកម្សាន្ត និងប្រកាសលេខ ១៧៦ ក.ប/ប្រ.ក ស្តីពីការអប់រំអនាម័យ និងបច្ចេកទេសសន្តិសុខការងារដល់កម្មករនិយោជិត នៅតាមមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន ០៨ខេត្ត (ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ ខេត្តតាកែវ ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តសៀមរាប )។

-សកម្មភាពអប់រំ ផ្សព្វផ្សាយដល់មន្ត្រីរាជការ សិស្ស និស្សិត កម្មករនិយោជិតស្តីពីយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១នៅកម្ពុជារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សរុបចំនួន ៥៦.០៣៦ នាក់ ( ស្ត្រី ៤១.១៥៦ នាក់ )។

**II-ការប្រជុំ និងការងារផ្សេងៗរបស់គណៈកម្មការសម្របសម្រួលត្រីភាគី(TCC)**

-កិច្ចប្រជុំលើកទី ៤ សម្រាប់ឆ្នាំ២០១៦ នៃគណៈកម្មការសម្របសម្រួលត្រីភាគីប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀននៅកន្លែងធ្វើការ ក្រោមអធិបតីភាព ឯកឧត្តមវេជ្ជ. **ហ៊ុយ ហានសុខ** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀន សរុបសមាជិកចូលរួម ៣៧ នាក់( ស្រី១៣នាក់) ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ នៅអគារទីស្តីការក្រសួង។

-ពិធីប្រកាសផ្សព្វផ្សាយដាក់ឲ្យប្រើប្រាស់នូវគោលការណ៍ណែនាំស្តីពីលក្ខខណ្ឌការងារវិធានអនាម័យ និងសន្តិសុខការងារនៃសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនផ្នែកសេវាកម្សាន្តដែលមានមន្ត្រីអធិការកិច្ចតែមួយ ម្ចាស់ ឬតំណាងម្ចាស់សហគ្រាស គ្រឹះស្ថានផ្នែកសេវាកម្សាន្ត សមាជិកសហជីព និងអង្គការមិនមែនរដ្ឋាភិបាល ចូលរួមចំនួន ១៨២ នាក់ ( ស្ត្រី ៣៣នាក់ ) ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ នៅទីស្តីការក្រសួង ក្រោមកិច្ចសហការជាមួយអង្គការ ILO ។

-កិច្ចប្រជុំពិគ្រោះយោបល់ពីការបង្កើតគោលការណ៍ណែនាំស្តីពីគិលានដ្ឋានសហគ្រាសក្រោមអធិបតីភាព ឯកឧត្តមវេជ្ជ. **ហ៊ុយ ហានសុខ** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍សរុបសមាជិកចូលរួម ៤០នាក់ ( ស្រី ១៥

នាក់)ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧ នៅសណ្ឋាគារភ្នំពេញ ក្រោមកិច្ចសហការជាមួយអង្គការ UNFPA Population Council ។

-សិក្ខាសាលាផ្សព្វផ្សាយការអនុវត្តប្រកាសលេខ ១៩៤ក.ប/ប្រ.កស្តីពីលក្ខខណ្ឌការងារ វិធានអនាម័យ និងសន្តិសុខការងារនៃសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនផ្នែកសេវាកម្សាន្ត និងការបៀតបៀននៅកន្លែងធ្វើការដែលមានម្ចាស់ ឬតំណាងម្ចាស់សហគ្រាស គ្រឹះស្ថានផ្នែកសេវាកម្សាន្តចំនួន ០៣ វគ្គ មានសិក្ខាកាមចូលរួមចំនួន ៥០ នាក់ ( ស្ត្រី ២១នាក់ )នៅខេត្តកំពង់ចាម និងខេត្តបាត់ដំបងសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

-កិច្ចប្រជុំ៤ លើករបស់ក្រុមការងារកសាងកម្រងព័ត៌មានជាតិស្តីពីសារធាតុ Asbestos នៃព្រះរាជាណាចក្រកម្ពុជា សរុបសមាជិកចូលរួមចំនួន ១៦១ នាក់ ( ស្ត្រី ៣៥នាក់ ) ក្រោមកិច្ចសហការជាមួយអង្គការ APHEDA ។

-សិក្ខាសាលាស្តីពីការលើកកម្ពស់សមត្ថភាព និងការពង្រឹកយន្តការឆ្ពោះទៅរកការលុបបំបាត់សារធាតុអាសបេស្តុសនៃព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានក្រុមការងារកសាងកម្រងព័ត៌មានជាតិស្តីពីសារធាតុអាសបេស្តុសនៃព្រះរាជាណាចក្រកម្ពុជាថ្ងៃទី១០-១៤ ខែកក្កដា ឆ្នាំ២០១៧នៅសណ្ឋាគារសោមាទេវីអង្គរខេត្តសៀមរាប ដោយមានសិក្ខាកាមចូលរួមសរុបចំនួន ៥០នាក់ (ស្រី ០៨នាក់) ក្រោមកិច្ចសហការជាមួយអង្គការ APHEDA។

-កិច្ចប្រជុំពិគ្រោះយោបល់ពីការបង្កើតគោលការណ៍ណែនាំស្តីពីគិលានដ្ឋានសហគ្រាសក្រោមអធិបតីភាព ឯកឧត្តមវេជ្ជ. **ហ៊ុយ ហានសុខ** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍សរុបសមាជិកចូលរួម ៦៥នាក់ ( ស្រី ៤១ នាក់)ថ្ងៃទី០៩ខែឧសភាឆ្នាំ២០១៧ នៅសណ្ឋាគារភ្នំពេញក្រោមកិច្ចសហការជាមួយអង្គការUNFPA Population Council ។

**III-ការងារអប់រំអេដស៍ដល់ពលករត្រៀមទៅធ្វើការនៅប្រទេសកូរ៉េ(៥មេរៀន)**

-បានផ្តល់ចំណេះដឹងពីស្ថានភាព មូលដ្ឋានគ្រឹះមេរោគអេដស៍ និងជំងឺអេដស៍ ជំងឺកាមរោគ គ្រឿងញៀន ការប្រើស្រោមអនាម័យដល់ពលករត្រៀមចាកចេញទៅធ្វើការនៅប្រទេសកូរ៉េរៀបចំនៅវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា(NPIC)ចំនួន១០វគ្គ សរុប ១.៣៤៩ នាក់ ក្នុងនោះស្ត្រីចំនួន ២៧៥នាក់ និងបុរស ១.០៧៤នាក់ (ឧស្សាហកម្ម ៦៩១ នាក់ កសិកម្ម ៥៦២នាក់ និងសំណង់៩៦នាក់) (ជូនភ្ជាប់នូវតារាងឧបសម្ព័ន្ធ)។

**IV-ការងារចូលរួមប្រជុំ និងសិក្ខាសាលាជាមួយស្ថាប័នពាក់ព័ន្ធ**

-កិច្ចប្រជុំផ្សព្វផ្សាយផែនការស្តីពីយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១ នៅកម្ពុជា (ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧) រៀបចំដោយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនចូលរួមដោយ ឯកឧត្តម **ឡេង សៃ** អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាអនុប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍និងគ្រឿងញៀន និងលោកស្រី **ម៉ៅ ធីតា** អគ្គនាយករងនៃអគ្គនាយកដ្ឋានការងារ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦ នៅវិទ្យាស្ថាន

ជាតិអប់រំ។

-ចូលរួមជាគណៈអធិបតីក្នុងសិក្ខាសាលាពិគ្រោះយោបល់ការប្រឈមដែលកំណត់ដោយកម្មការិនីផ្នែកសំណង់ ចូលរួមដោយ លោកស្រី **ខា សុខនី** អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ នៅភោជនីយដ្ឋានទន្លេបាសាក់ ២ ក្រោមកិច្ចសហការជាមួយអង្គការ CARE ។

-កិច្ចប្រជុំស្តីពីការរៀបចំសេចក្តីព្រាងគណៈកម្មាធិការប្រយុទ្ធគ្រឿងញៀនចំរុះអន្តរក្រសួងសម្រាប់យុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១រៀបចំដោយលេខាធិការដ្ឋានយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ចូលរួមដោយ លោកស្រី **ម៉ៅ ធីតា** អគ្គនាយករងនៃអគ្គនាយកដ្ឋានការងារ ថ្ងៃទី០២ ខែមករា ឆ្នាំ២០១៧ នៅក្រសួងមហាផ្ទៃ។

-កិច្ចប្រជុំស្តីពីរយៈពេល១០ថ្ងៃនៃយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១រៀបចំដោយលេខាធិការដ្ឋានយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនចូលរួមដោយ លោកស្រី **ម៉ៅ ធីតា** អគ្គនាយករងនៃអគ្គនាយកដ្ឋានការងារ ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧ នៅអគ្គស្នងការនគរបាលជាតិ។

-ទស្សនកិច្ចនៅបណ្ណាល័យមណ្ឌលធនធានក្នុងរោងចក្រ Dewhirst Cambodia ស្តីពីសកម្មភាពអប់រំដល់កម្មករដោយអង្គការ CWPD និងថ្នាក់អក្ខរកម្មដោយរោងចក្រ Dewhirst Cambodia ចូលរួមដោយ លោក **អ៊ុំ វីរៈ** នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧ រៀបចំដោយអង្គការSIPAR។

-កិច្ចប្រជុំបូកសរុបលទ្ធផលយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី ១ប្រចាំខែមករាឆ្នាំ២០១៧ និងពិធីប្រកាសសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការចម្រុះប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ក្រោមអធិបតីភាព សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចូលរួមដោយ ឯកឧត្តមវេជ្ជ. **ហ៊ុយ ហានសុខ** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀន និងលោកស្រី **ម៉ៅ ធីតា** ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៧ នៅក្រសួងមហាផ្ទៃ។

-កិច្ចប្រជុំគណៈកម្មការទទួលបន្ទុកផ្សព្វផ្សាយអប់រំអន្តរក្រសួងស្តីពីយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី ១ ចូលរួមដោយ ឯកឧត្តមវេជ្ជ. **ហ៊ុយ ហានសុខ** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀន ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ នៅអគ្គស្នងការដ្ឋាននគរបាលជាតិ។

-កិច្ចប្រជុំត្រួតពិនិត្យលទ្ធផលការងារប្រចាំអឌ្ឍមាសខែកុម្ភៈឆ្នាំ២០១៧ របស់លេខាធិការដ្ឋាននៃយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី ១ ចូលរួមដោយ លោកស្រី **ម៉ៅ ធីតា** ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ នៅអគ្គស្នងការដ្ឋាននគរបាលជាតិ។

-កិច្ចប្រជុំត្រួតពិនិត្យលទ្ធផលការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១ប្រចាំខែកុម្ភៈឆ្នាំ២០១៧ ក្រោមអធិបតីភាព សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចូលរួមដោយ ឯកឧត្តមវេជ្ជ. **ហ៊ុយ ហានសុខ** រដ្ឋលេខាធិការក្រសួង



5

ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀន និងលោកស្រី **ម៉ៅ ធីតា** ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៧ នៅក្រសួងមហាផ្ទៃ។

-សិក្ខាសាលាពិគ្រោះយោបល់ស្តីពីលទ្ធផលស្រាវជ្រាវរបស់គម្រោងសុខភាពកម្មករ រៀបចំដោយ UNFPA ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ នៅសណ្ឋាគារឡឺរ៉ូយ៉ាល់។

-កិច្ចប្រជុំប្រចាំខែកុម្ភៈឆ្នាំ២០១៧ និងទិសដៅបន្តយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១ ចូលរួមដោយលោកស្រី **ម៉ៅ ធីតា** ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧នៅអគ្គស្នងការនគរបាលជាតិ។

-កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់នៃប្រទេសហត្ថលេខីអនុស្សរណៈនៃការយោគយល់គ្នា(MOU) ស្តីពីការត្រួតពិនិត្យគ្រឿងញៀនក្នុងមហាអនុតំបន់ទន្លេមេគង្គ ចូលរួមដោយ លោកស្រី **ម៉ៅ ធីតា** អគ្គនាយករងនៃអគ្គនាយកដ្ឋានការងារ ថ្ងៃទី ០៨-១១ ខែឧសភា ឆ្នាំ២០១៧ នៅរ៉ាហ្វលឡឺរ៉ូយ៉ាល់ ។

-កិច្ចពិភាក្សាស្វែងរកការគាំទ្រសប្តាហ៍មោទនភាព និងទិវាអន្តរជាតិប្រឆាំងការរើសអើងអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា ចូលរួមដោយ លោកស្រី **សុខ ពុលិកា** ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៧ នៅភោជនីយដ្ឋានទន្លេបាសាក់២ ។

-កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់នៃប្រទេសហត្ថលេខីអនុស្សរណៈនៃការយោគយល់គ្នា(MOU) ស្តីពីការត្រួតពិនិត្យគ្រឿងញៀនក្នុងមហាអនុតំបន់ទន្លេមេគង្គ ចូលរួមដោយ លោកស្រី **ម៉ៅ ធីតា** អគ្គនាយករងនៃអគ្គនាយកដ្ឋានការងារ ថ្ងៃទី ០៨-១១ ខែឧសភា ឆ្នាំ២០១៧ នៅរ៉ាហ្វលឡឺរ៉ូយ៉ាល់ ។

-កិច្ចពិភាក្សាស្វែងរកការគាំទ្រសប្តាហ៍មោទនភាព និងទិវាអន្តរជាតិប្រឆាំងការរើសអើងអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា ចូលរួមដោយ លោកស្រី **សុខ ពុលិកា** ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៧ នៅភោជនីយដ្ឋានទន្លេបាសាក់២។

-កិច្ចប្រជុំបូកសរុបលទ្ធផលការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១ ក្រោមអធិបតីភាព សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចូលរួមដោយ ឯកឧត្តមវេជ្ជ. **ហ៊ុយ ហានសុខ** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍និងគ្រឿងញៀន ឯកឧត្តម **ឡេង សែ** អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាអនុប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀន និងលោកស្រី **ម៉ៅ ធីតា** អគ្គនាយករងនៃអគ្គនាយកដ្ឋានការងារថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៧ នៅក្រសួងមហាផ្ទៃ។

**ខ-<u>ទិសដៅអនុវត្តបន្ត</u>**

-បន្តផ្សព្វផ្សាយនិងណែនាំការចុះជំរុញការអនុវត្តប្រកាសលេខ០៨៦ ក.ក.ប.វ/ប្រ.កស្តីពីការបង្កើតគណៈ កម្មការអេដស៍នៅតាមសហគ្រាស គ្រឹះស្ថាននៅតាមរាជធានី ខេត្ត។

-កិច្ចប្រជុំក្រុមការងាររកសាងកម្រងព័ត៌មានជាតិស្តីពីសារធាតុអាសបេស្តុសនៃព្រះរាជាណាចក្រកម្ពុជា។

-សិក្ខាសាលាពង្រឹងសមត្ថភាពដល់មន្ត្រីអធិការកិច្ចការងារស្តីពីការជំរុញការអនុវត្តប្រកាសលេខ ១៩៤ ក.ប/ប្រ.ក ស្តីពីលក្ខខណ្ឌការងារ វិធានអនាម័យ និងសន្តិសុខការងារនៃសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនផ្នែកសេវាកម្សាន្ត នៅរាជធានី ខេត្ត។

-បន្តអប់រំពីមេរោគអេដស៍/ជំងឺអេដស៍ និងគ្រឿងញៀនដល់ពលករទៅធ្វើការនៅប្រទេសកូរ៉េ

-បន្តអប់រំផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នៅតាមសហគ្រាស គ្រឹះស្ថាន។

-បន្តកិច្ចសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍(NAA) អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អង្គការ SIPAR UNFPA និងអង្គការ APHEDA ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំបាទ។

រាជធានីភ្នំពេញថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៧

**ប្រធាន**

**វេជ្ជ. ហ៊ុយ ហានសុខ**

ចម្លងជូន:

-នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

-ឯកសារ-កាលប្បវត្តិ

## តារាងឧបសម្ព័ន្ធការអប់រំមេរោគអេដស៍/ជំងឺអេដស៍

| ល.រ | បរិយាយ | ភេទ | ប្រចាំឆមាស ឆ្នាំ២០១៧ | ប្រចាំឆមាស ឆ្នាំ២០១៦ | ប្រៀបធៀប (%) |
|---|---|---|---|---|---|
| | | | ១ | ២ | ៣=(១-២)/២ |
| ១ | ការអប់រំមេរោគអេដស៍/ជំងឺអេដស៍ដល់ពលករត្រៀមទៅធ្វើការនៅប្រទេសកូរ៉េ | សរុប | ១.៣៤៩ | ១.៦៧៣ | -១៩.៣៦ |
| | | ស្រី | ២៧៥ | ៥១៨ | -៤៦.៩១ |

ប្រភព៖ លេខាធិការដ្ឋានអេដស៍ និងគ្រឿងញៀនប្រចាំឆមាសឆ្នាំ២០១៧